ឥណទានថវិកាចំនួន ២៩ ២០០ លានរៀល ( ម្ភៃប្រាំបួនពាន់ពីររយលានរៀល ) ទៅលើសៀវភៅថវិការបស់ក្រសួងការពារជាតិ សំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៨ ។

មាត្រា ២ .- ឥណទានបន្ថែមដូចបានកំណត់ក្នុងមាត្រា១ ខាងលើត្រូវបានផ្តល់បន្ថែមនៅជំពូក ១១ ( ចំណាយដំណើរការរដ្ឋបាល សំភារៈនិងផ្គត់ផ្គង់ ) ចំនួន ២៨ ០៨០ លានរៀល និង ជំពូក ៣១ ( អន្តរាគមន៍ក្នុងវិស័យសេដ្ឋកិច្ច និង វប្បធម៌ ) ចំនួន ១ ១២០ លានរៀល ដើម្បីធានាចំណាយបង់លើកិច្ចសន្យាខ្ចីទំនិញទាំង ៥ មុខ ក្នុងនោះរួមមាន សំភារៈឧបករណ៍វិស្វកម្ម ប្រេងឥន្ធនៈ សំភារៈយោធភ័ណ្ឌ ឱសថ និង សំភារៈបច្ចេកទេស របស់ក្រសួងការពារជាតិ សំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៨ ជាមួយក្រុមហ៊ុន សូ ពីអ៊ិច ។

មាត្រា ៣ .- ការបែងចែកឥណទានបន្ថែមផ្ទៃក្នុងជំពូក តាមប្រការ កថាខណ្ឌ និង វាក្យខណ្ឌ ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

មាត្រា ៤ .- ឥណទានថវិកាបន្ថែមនេះ ត្រូវរដ្ឋសភាពិនិត្យអនុម័តជាបន្ទាន់ភ្ជាប់ក្នុងច្បាប់ហិរញ្ញវត្ថុ បន្ថែមមួយ ការបើកចំណាយពិសេសនេះត្រូវបានចាប់សព្វគ្រប់ ។

មាត្រា ៥ .- សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៩៨

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខា និង ត្រា

អ៊ឹង ហួត ហ៊ុន សែន

★ ★ ★

## អនុក្រឹត្យលេខ ៥៨ អនក្រ.បក
## ស្តីពីការផ្តល់ឥណទានថវិកាបន្ថែម ចំនួន ៣.៨០០ លានរៀល ( បីពាន់ប្រាំបីរយលានរៀល ) ទៅលើឥណទានថវិការបស់ក្រសួង មហាផ្ទៃ សំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៨

***

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេច ព្រះនរោត្តម សីហនុ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨៩៧/១៥៧ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល

-បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

-បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦

-បានឃើញច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០១ នស/៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣

-បានឃើញច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ១៩៩៨ ដែលប្រកាសអោយប្រើ ដោយព្រះរាជក្រមលេខ នស/រកម/០១៩៨/០១ ចុះថ្ងៃទី ៩ ខែ មករា ឆ្នាំ ១៩៩៨

-បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ១៩៩៨ របស់រាជរដ្ឋាភិបាល ស្តីពីការបែងចែកឥណទានតាមជំពូកនៃច្បាប់ ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៨

-បានឃើញប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លេខ ០០៥ ប្រ.ក.សហវ.ថ ចុះថ្ងៃទី ២៧ ខែ មករា ឆ្នាំ ១៩៩៨ ស្តីពីការបែងចែកឥណទានផ្ទៃក្នុងជំពូក តាមប្រការ កថាខ័ណ្ឌ វាក្យខ័ណ្ឌ សំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៨

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

**សំរេច**

មាត្រា ១ ._ ដោយអនុលោមទៅតាមមាត្រា ៥៦ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០១ នស/៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ត្រូវបានអនុញ្ញាតផ្តល់បន្ថែមឥណទានថវិកាចំនួន ៣.៨០០ លានរៀល ( បីពាន់ប្រាំបីរយលានរៀល ) លើសេចក្តីសៀវភៅថវិការបស់ក្រសួងមហាផ្ទៃ ផ្នែកសន្តិសុខសាធារណៈសំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៨ ។

មាត្រា ២ ._ ឥណទានបន្ថែមដូចបានកំណត់ក្នុងមាត្រា១ ខាងលើត្រូវបានផ្តល់បន្ថែមនៅជំពូក១១ ( ចំណាយដំណើរការរដ្ឋបាល សំភារៈនិងផ្គត់ផ្គង់តូច ) របស់ក្រសួងមហាផ្ទៃ ផ្នែកសន្តិសុខសាធារណៈ សំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៨ ដើម្បីធានាចំណាយទូទាត់ឯកសណ្ឋានសំភារៈ និងបរិក្ខារជំនាញកងកំលាំងនគរបាលជាតិ បំពេញបង្គ្រប់របបប្រចាំ ឆ្នាំ ១៩៩៨ ជូនក្រុមហ៊ុន ស្ស ពីអ៊ិច ចំនួន ២.៦៤០ លានរៀល និង ក្រុមហ៊ុន តូ ហ៊្វឹឡុង ចំនួន ១.១៦០ លានរៀល ។

មាត្រា ៣ ._ ការបែងចែកឥណទានបន្ថែមផ្ទៃក្នុងជំពូក តាមប្រការ កថាខ័ណ្ឌ និង វាក្យខ័ណ្ឌ ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

មាត្រា ៤._ ឥណទានថវិកាបន្ថែមនេះ ត្រូវរដ្ឋសភាពិនិត្យអនុម័តជាបន្ទាន់ភ្លាមក្នុងច្បាប់ហិរញ្ញវត្ថុបន្ថែមមួយ កាលបើចំណាយពិសេសនេះត្រូវបានចប់សព្វគ្រប់ ។

មាត្រា ៥ ._ សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៩៨

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខា និង ត្រា

អ៊ឹង ហួត ហ៊ុន សែន

★ ★ ★

## អនុក្រឹត្យលេខ ១៩១ អនក្រ.តត

## ស្តីពីការតែងតាំងប្រធានគណៈកម្មាធិការ POW/MIA កម្ពុជា

***

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

-បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ និង ព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ និង ព្រះរាជក្រឹត្យលេខ ជស/រកត/០៨៩៧/១៥៧ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា

-ផ្អែកតាមស្ថានភាពពិតប្រាកដ និងការចាំបាច់របស់ព្រះរាជាណាចក្រកម្ពុជា

### សំរេច

មាត្រា ១ ._ តែងតាំងឯកឧត្តម ឧត្តមសេនីយ៍ឯក ម៉ុល សារឿន នាយរងអគ្គសេនាធិការ នៃកងយោធពលខេមរភូមិន្ទ អោយទទួលបន្ទុកបន្ថែមជា ប្រធានគណៈកម្មាធិការ POW/MIA-កម្ពុជា ជំនួសឯកឧត្តម នួន សារ៉េត ដែលបានទៅបំពេញភារកិច្ចថ្មី ។

មាត្រា ២ ._ តែងតាំងឯកឧត្តម អ៊ុង ស៊ាន អនុរដ្ឋលេខាធិការក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ អោយទទួលបន្ទុកបន្ថែមជា អនុប្រធានគណៈកម្មាធិការ POW / MIA-កម្ពុជា ជំនួសលោកជំទាវ ម៉ុក ម៉ារីណា ។

មាត្រា ៣ ._ សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសុខាភិបាល នាយអគ្គសេនាធិការនៃកងយោធពលខេមរភូមិន្ទ